# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥/០៩/២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០/០៧/១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ចុះថ្ងៃទី ២៤/០៨/២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជសង្ឃប្រកាស លេខ ០០១/០៦ ម.ស.រ.ធ.ត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ព.ស ២៥៥០ / គ.ស ២០០៦ ស្តីពីការកំណត់បែងចែកភារកិច្ចសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញសង្ឃប្រកាសលេខ ៣៣.សករ.វ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់ករណីយកិច្ចនៃចៅអធិការ អនុគណ មេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ១៩៦២ បានសំរេចហើយនោះទុកជាករណីយកិច្ចថាវរមាន ដើម្បីបន្តអនុវត្តសម្រាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនាតទៅ
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

Downloaded from http://www.khmerlaws.com

# ស ម្រេ ច

**មាត្រា១** : ត្រូវបានបង្កើតថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ជាសហធម្មិក ឱ្យថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជំនុំជម្រះដោះស្រាយអធិករណ៍ ដែលមានសមាសភាព ដូចខាងក្រោមនេះ :

**ក. ថេរសភារាជធានី-ខេត្ត**

| | |
|---|---|
| ១- ព្រះមេគណរាជធានី-ខេត្ត | ប្រធាន |
| ២- ព្រះបាឡាត់គណរាជធានី-ខេត្ត | អនុប្រធានទី ១ |
| ៣- ព្រះវិន័យធរគណរាជធានី-ខេត្ត | អនុប្រធានទី ២ |
| ៤- ព្រះធម្មធរគណរាជធានី-ខេត្ត | សមាជិក |
| ៥- ព្រះសមុហ៍គណរាជធានី-ខេត្ត | សមាជិក |
| ៦- ព្រះលេខាគណរាជធានី-ខេត្ត | សមាជិក |

**ខ. ថេរសភាក្រុង-ស្រុក-ខណ្ឌ**

| | |
|---|---|
| ១- ព្រះអនុគណក្រុង-ស្រុក-ខណ្ឌ | ប្រធាន |
| ២- ព្រះវិន័យធរអនុគណក្រុង-ស្រុក-ខណ្ឌ | អនុប្រធានទី ១ |
| ៣- ព្រះធម្មធរអនុគណក្រុង-ស្រុក-ខណ្ឌ | អនុប្រធានទី ២ |
| ៤- ព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ | សមាជិក |
| ៥- ព្រះលេខាអនុគណក្រុង-ស្រុក-ខណ្ឌ | សមាជិក |

**មាត្រា២** : ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូច ខាងក្រោម:

**ក. ថេរសភារាជធានី-ខេត្ត**

- ជាសហធម្មិកសង្ឃរបស់ថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃ ជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅរាជធានី-ខេត្ត និងតាមសំណើបញ្ជូនរបស់ថេរសភាក្រុង-ស្រុក-ខណ្ឌ
- ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលកើតមានឡើងនៅតាមវត្តអារាម ឬ អាស្រម
- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន

Downloaded from http://www.khmerlaws.com

- រកគ្រប់វិធី ធ្វើការណែនាំ កោះហៅ សម្រុះសម្រួលនូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាព ក្នុងពុទ្ធសាសនមណ្ឌល
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍និមួយៗ ដោយឈរលើទស្សនៈ គ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាច អគតិធម៌ទាំង ៤
- អធិករណ៍ដែលថេរសភារាជធានី-ខេត្ត មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនមកគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីដោះស្រាយ ។
- អធិករណ៍ដែលគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនមកថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជំនុំជម្រះដោះស្រាយបិទផ្លូវតវ៉ា
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ស្នើឱ្យជួយដោះស្រាយ
- ការដោះស្រាយអធិករណ៍ត្រូវមានតំណាងមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ជាអ្នកពិគ្រោះយោបល់ និងសង្កេតការ ក្នុងការដោះស្រាយអធិករណ៍ ។

**ខ. ថេរសភាក្រុង-ស្រុក-ខណ្ឌ**

- ជាសហធម្មិកសង្ឃរបស់ថេរសភានៃព្រះពុទ្ធសាសនារាជធានី/ខេត្ត ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃជំនុំជម្រះនិងដោះស្រាយរម្ងាប់អធិករណ៍ដែលកើតមានឡើងនៅក្រុង-ស្រុក-ខ័ណ្ឌ
- ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលកើតមានឡើងនៅតាមវត្តអារាម ឬ អាស្រម
- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន
- រកគ្រប់វិធី ធ្វើការណែនាំ កោះហៅ សម្រុះសម្រួលនូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាព ក្នុងពុទ្ធសាសនមណ្ឌល
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស

Downloaded from http://www.khmerlaws.com

- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍និមួយៗ ដោយឈរលើទស្សនៈ គ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង ៤
- អធិករណ៍ដែលថេរសភាក្រុង-ស្រុក-ខណ្ឌ មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនសុំណុំរឿងមកថេរសភារាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីដោះស្រាយ
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលថេរសភា នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា និងថេរសភារាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យជួយដោះស្រាយ
- ការដោះស្រាយអធិករណ៍ត្រូវមានការិយាល័យធម្មការ និងសាសនា ជាអ្នកពិគ្រោះយោបល់ និងសង្កេតការ ក្នុងការដោះស្រាយអធិករណ៍ ។

**មាត្រា៣ :** ការតែងតាំងសមាសភាពថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមគោរណីកាណីតែងតាំងក្នុងព្រះរាជសង្ឃប្រកាស លេខ ០០១/០៦ ម.ស.រ.ធ.គ ស្ដីពីការកំណត់បែងចែកភារកិច្ចសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជ និងសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ព.ស ២៥៥០ / គ.ស ២០០៦ ។

**មាត្រា៤ :** ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំដោយព្រះសមុហ៍គណរាជធានី-ខេត្ត និងព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ ជាលេខាធិការ ត្រូវធ្វើរបាយការណ៍ជាប្រចាំទូលថ្វាយតាមឋានានុក្រម មកគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជូនក្រសួងធម្មការ និងសាសនា ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

**មាត្រា៥ :** លេខាធិការដ្ឋានថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន តាមព្រះសង្ឃប្រកាសរបស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងមានការយល់ព្រមពីក្រសួងធម្មការ និងសាសនា ។

**មាត្រា៦ :** ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា សំរាប់ប្រតិបត្តិការរបស់ខ្លួន។

**មាត្រា៧ :** បទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

Downloaded from http://www.khmerlaws.com

**មាត្រា៨ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន រាជធានី/ខេត្ត និងសាមីអង្គ ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

**មិន ឃិន**

***កន្លែងទទួល***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com